ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 09 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

001/18-07-2007-ECCC/TC
E1/43

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 15 / 09 / 09
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Fuy

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះករណី "ឌុច"
# សាធារណៈ:

## សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ
## ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ -ថ្ងៃជំនុំជម្រះទី៣៨

រៀបចំដោយ: **សែ កុលវុឌ្ឍី** និង Natacha WEXELS-RISER

| |
|---|
| <u>កំណត់ហេតុអ្នកចូលរួម</u> |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖ លោក Crippa MATTEO, លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Natacha Wexels-Riser, លោក លឹម ស៊ុយហុង |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Robert Petit , លោក ពេជ្រ សម្បត្តិ លោក Zachery Lampell, លោក ប៉ាក ចន្ទលីណូ, កញ្ញា ជុន សុលក្ខណ៍, លោក Jacopo Rossi. |



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. E.C.T.C.

| |
|---|
| ជនជាប់ចោទ៖ លោក កាំង ហ្កេចអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក François Roux(អវត្តមាន), លោកស្រី Marie-Paule Canizares, លោកស្រី Heleyn Unac,លោក ចាន់ រ៉ាវុធ, លោក Alexandre Prezanti |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ កញ្ញា Silke Studzinsky, លោក យ៉ុង ផានិត, លោកស្រី Martine Jacquin, កញ្ញា ម៉ុច សុវណ្ណារី, កញ្ញា ទី ស្រីនណា, លោក Alain Werner, លោក ហុង គឹមសួន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក សាន គីរី, លោកស្រី Julie Massé, លោក Scott Bywater |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩ | ចាប់ផ្ដើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកព្រឹក | ចាប់ផ្ដើមម៉ោង៖១០.៣៥ | បញ្ចប់ម៉ោង៖១១.០០ |
| សម្រាក | ចាប់ផ្ដើមម៉ោង៖១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកល្ងាច | ចាប់ផ្ដើមម៉ោង៖ ១៤.៣០ | បញ្ចប់ម៉ោង៖ ១៤.៥០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៥ ម៉ោង |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការជូនដំណឹងទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី E2/43 | មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី ១ | ៩.០៣ | ៩.០៦ |
| ការស្នើសុំពេលវេលាបន្ថែមសម្រាប់ការធ្វើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី E2/32 | មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុមទី ២ | ៩.០៦ | ៩.០៨ |
| សេចក្ដីសម្រេចស្ដីពីការដកឈ្មោះសាក្សី KW-24 ពីបញ្ជីឈ្មោះសាក្សី | អង្គជំនុំជម្រះ | ៩.១២ | ៩.១៧ |
| ការតាំងសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី លី ហ៊ី (E2/61) | អង្គជំនុំជម្រះ | ៩.១៩ | ១៣.៥៧ |

00375626



| | | | |
|---|---|---|---|
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា (E2/61) | សហព្រះរាជអាជ្ញា | ១៣.៥៨ | ១៤.០០ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា (E2/61) | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១(១៤.០១ ដល់១៤.៣០ និង ១៤.៥២ ដល់ ១៤.៥៤) ក្រុមទី៣ (១៤.៥៥ ដល់១៤.៥៩) ក្រុមទី៤(១៤.៥៩ដល់១៥.០១) | ១៤.០១ | ១៥.០១ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា(E2/61) និងការកត់សម្គាល់របស់មេធាវីការពារក្តី និងស្នើសុំឲ្យប្រគល់គ្រប់ឯកសារទាំងអស់ដែលទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ទៅមេធាវីការពារក្តីជាភាសាខ្មែរ និងបារាំង | មេធាវីការពារក្តី (១៥.០៦ ដល់ ១៥.០៩ និង ១៥.៣៤ ដល់ ១៥.៥១) | ១៥.០៦<br>១៥.៣៤ | ១៥.០៩<br>១៥.៥១ |
| ការកត់សម្គាល់របស់ជនជាប់ចោទ | ជនជាប់ចោទ | ១៥.០៩ | ១៥.២៥ |
| ការពិភាក្សាដេញដោល | អង្គជំនុំជម្រះ | ១៥.៥២ | ១៦.០១ |

<u>**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**</u>

**ការជូនដំណឹងទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ បានដកនូវសំណើក្នុងការស្តាប់នូវសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីE2/43 និងបានជូនដំណឹងថាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមែនជាអ្នករស់រានមានជីវិតទាំងអស់ ត្រូវការរយៈពេលសរុប ៣៥ ម៉ោង សម្រាប់ការធ្វើសេចក្តីថ្លែងការណ៍របស់ពួកគេ។

**សំណើសុំពេលវេលាបន្ថែមដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី២ បានស្នើសុំនូវរយៈពេលវេលាបន្ថែម០.៥ថ្ងៃ ...



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C. C.E.T.C.

ការធ្វើសេចក្តីថ្លែងការរបស់ដើមបណ្តឹងរដ្ឋប្បវេណី E2/32។

**សេចក្តីសម្រេចដោយផ្ទាល់មាត់ទាក់ទងនឹងការដកសាក្សី** KW-24 **ពីបញ្ជីឈ្មោះសាក្សី**

អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចក្នុងការដកសាក្សី KW-24 ពីបញ្ជីឈ្មោះសាក្សី(សូមមើលខាងក្រោម)។

**ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា** E2/61

- មេធាវីការពារក្តីបានបញ្ជាក់ពីភាពមន្ទិលសង្ស័យដែលថា ដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា ត្រូវបានជាប់ឃុំនៅមន្ទីរស២១នោះ។
- អង្គជំនុំជម្រះបានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១ រួមបញ្ចូលទាំងជើងឯក និង មន្ទីរស២៤។
- សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ និង ៣ ក៏ដូចជាមេធាវីការពារក្តីបានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី លី ហ៊ា ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការណ៍មន្ទីរស២១រួមបញ្ចូលទាំងជើងឯក។ ជនជាប់ចោទបានធ្វើការកត់សម្គាល់ខ្លះៗទៅលើសក្ខីកម្មនោះ។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧.៣**

| លេខយោងរបស់អជសជ | លេខយោងរបស់កសចស | ឈ្មោះ/ការអធិប្បាយ | ចំណាត់ថ្នាក់ឯកសារ (សំងាត់បំផុត សំងាត់ ឬសាធារណៈ) | កំណត់សម្គាល់ |
|---|---|---|---|---|
| E2/61.1 | គ្មាន | ឧបសម្ព័ន្ធ១៖ លិខិតបញ្ជាក់របស់ លី ហ៊ា ពីពត៌មានស្តីពីឧក្រិដ្ឋកម្មដែលត្រូវចោទ | សាធារណៈ | 00280015-00280017 ជាពិសេស 00280015 |
| E2/61.2 | គ្មាន | ឧបសម្ព័ន្ធ២៖ ជីវប្រវត្តិរបស់ អ៊ា ហ៊ា | សាធារណៈ | 00279915-00279930 ជាពិសេស 00279927 |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី- ០៦ កក្កដា ២០០៩ /សាធារណៈ

E.C.C.C. TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE

| | | | | |
|---|---|---|---|---|
| | | | | 00279929,00279930<br>00360995-00361007<br>00361722-00361729 |
| E3/390 | D2-3 | កំណត់ហេតុសួរចម្លើយ ឈាង ឈាង | សាធារណៈ: កោសលុប | 00145548-00145556<br>00146771,00147713-00147715<br>កោសលុបពត៌មានផ្ទាល់ខ្លួន |
| E3/391 | IS 4.20 | កងពលខ្មែរក្រហម ៧០៣ | សាធារណៈ: | 00081277-00081488<br>00192933-00193063 |
| E3/381 | D57<br>ឧបសម្ព័ន្ធ៣ | ឧបសម្ព័ន្ធ៣៖ ប្រវត្តិសង្ខេបអ្នកដែលបានដោះលែង(អ្នកទោសដែលបានដោះលែងក្នុងកងពល ៧០៣) | សាធារណៈ: | 00316312-00316318<br>មាននៅក្នុងE3រួចហើយ |
| E3/231 | IS 14.3 | ស២១ កំណត់ដៃរបស់ម៉ម ណៃ ហៅ ចាន់ | សាធារណៈ: | 00077661-00078056<br>ជាពិសេស 00077976<br>00077978,00077979<br>00184579-00184618<br>00224410-0022441<br>មាននៅក្នុងE3រួចហើយ |
| E5/2.8 | គ្មាន | ស២១ ចម្លើយសារភាពរបស់ ឈាវ ស៊ុនហេង | សាធារណៈ: | 00283986-00283986<br>00226555-00226580 |
| E2/61 | គ្មាន | ទម្រង់បែបបទពត៌មានជនរងគ្រោះ លី ហ៊ | សាធារណៈ: កោសលុប | 00279954-00279959<br>00360821-00360824<br>00362243-00362251<br>កោសលុបពត៌មានផ្ទាល់ខ្លួន |
| E2/61/1 | គ្មាន | របាយការណ៍របស់អង្គភាពជនរងគ្រោះទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលី ហ៊ | សាធារណៈ: កោសលុប | 00279934-00279935<br>00369439-00369440<br>កោសលុបពត៌មានផ្ទាល់ខ្លួន |
| E68.1 | គ្មាន | បញ្ជីឈ្មោះអ្នកទោសស២១ | សាធារណៈ: | 00329596-00330129 |



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E.C.C.C.

00375629

001/18-07-2007-ECCC/TC
E1/43

| | | | | |
|---|---|---|---|---|
| | | ដែលបានកែតម្រូវ | | ជាពិសេស 00329681. បានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ |

ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖

- **សេចក្តីសម្រេចលើការដកសាក្សី** KW-24 **ចេញពីបញ្ជីឈ្មោះសាក្សី**

អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបដល់ភាគី និងសាធារណៈជនអំពីសេចក្តីសម្រេចរបស់ខ្លួនទាក់ទងនឹងសាក្សី KW-24។

**អំពីអង្គហេតុ**

នៅថ្ងៃច័ន្ទទី ២៩ ខែកក្កដា ឆ្នាំ ២០០៩ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីនានាអំពីសេចក្តីសម្រេចរបស់ខ្លួនលើការដកចេញនូវសាក្សីមួយចំនួនចេញពីបញ្ជីឈ្មោះសាក្សីដែលនឹងត្រូវកោះហៅដើម្បីមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

អង្គជំនុំជម្រះបានស្នើសុំនូវមតិយោបល់របស់ភាគីអំពីការដកចេញនូវសាក្សី KW-24 ចេញពីបញ្ជីឈ្មោះសាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

សហព្រះរាជអាជ្ញាបានស្នើសុំលទ្ធភាពពិភាក្សាលើបញ្ហានេះនៅក្នុងសវនាការជាលក្ខណៈអសាធារណៈ ឬធ្វើការកត់សម្គាល់របស់ខ្លួនជាលាយលក្ខណ៍អក្សរ។ អង្គជំនុំបានអនុញ្ញាតអោយសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនជាលាយលក្ខណ៍អក្សរដែលនឹងត្រូវដាក់ជូនអង្គជំនុំជម្រះយ៉ាងយូរបំផុតត្រឹមថ្ងៃអង្គារ ទី ៣០ ខែមិថុនា ឆ្នាំ ២០០៩ វេលាម៉ោង ៤ និង ៣០ នាទីល្ងាច។ ដើមបណ្តឹងរដ្ឋប្បវេណី មិនមានសេចក្តីអធិប្បាយទៅលើបញ្ហាដែលបានលើកឡើងនេះទេ។ ចំណែកមេធាវីការពារក្តីក៏មិនបានធ្វើការជំទាស់ទៅលើសំណើដកសាក្សីនេះទេ។

នៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួនដែលឯកសារត្រូវបានចាត់ថ្នាក់ជាប្រភេទឯកសារសំងាត់ដើម្បីស្នើទុកសាក្សី KW-24 ក្នុងបញ្ជីឈ្មោះសាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។

សហព្រះរាជអាជ្ញាបានលើកឡើងថា សាក្សី KW-24 គឺជាសាក្សីតែម្នាក់គត់ដែលបានយល់ដឹងច្បាស់និងមានបទពិសោធយ៉ាងច្រើនទាក់ទងនឹងប្រតិបត្តិការនៅជើងឯក។ សក្ខីកម្មរបស់សាក្សីរូបនេះគឺជា

ជាមានសារៈសំខាន់ក្នុង ការផ្តល់នូវការពិតអំពីឧក្រិដ្ឋកម្មទាំងឡាយដែលបានកើតមាននៅទីនោះ ហើយដែលសាក្សីផ្សេងទៀត ក្រៅពីសាក្សីរូបនេះមិនអាចនឹងធ្វើបានដូច្នេះ។ សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា អត្ថប្រយោជន៍ដែលនឹងបានពីការស្តាប់សក្ខីកម្មរបស់សាក្សី KW-24 ដោយអង្គជំនុំជម្រះ គឺមានទម្ងន់និងតំលៃលើសពីអ្វីដែលអង្គជំនុំជម្រះគិតថាជាការខាតបង់ពេលវេលាបន្ថែមនោះ។

## អំពីសម្អាងហេតុ

អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សក្ខីកម្មរបស់សាក្សី KW-24 គឺមានជាប់ទាក់ទងនឹងអង្គហេតុដែលសាក្សីផ្សេងទៀតនឹងត្រូវមកផ្តល់សក្ខីកម្មផងដែរ។ អង្គជំនុំជម្រះមិនយល់ឃើញថាសក្ខីកម្មរបស់សាក្សីរូបនេះនឹងអាចផ្តល់នូវព័ត៌ដែលមិនអាចរកបានតាមរយៈមធ្យោបាយផ្សេងនោះឡើយ។ ដោយគិតពិចារណាទៅដល់ការជំនុំជម្រះមួយដែលប្រកបដោយភាពយុត្តិធម៌ និងឆាប់រហ័សនោះ អង្គជំនុំជម្រះយល់ថាវាមិនជាការចាំបាច់ទេក្នុងការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះសូមបញ្ជាក់ថាកំណត់ហេតុជាលាយលក្ខអក្សរដែលបានធ្វើចំពោះសាក្សីរូបនេះនៅដំណាក់កាលស៊ើបអង្កេតនិងត្រូវយកមកដាក់នៅចំពោះមុខអង្គជំនុំជម្រះស្របតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង។

## សេចក្តីសម្រេច

អង្គជំនុំជម្រះសម្រេចដកសាក្សី KW-24 ចេញពីបញ្ជីឈ្មោះសាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំសាលាដំបូង។

- បង្គាប់ឲ្យនាំជនជាប់ចោទត្រឡប់ទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកកាន់សាលសវនាការវិញនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ ។

<u>ដីកាសម្រាប់ការលើកវារកាលសវនាការ</u>

ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃអង្គារ ទី០៧ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង ៩.០០ ព្រឹក ។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E.C.C.C.

ភ្នំពេញ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ កុលខុន Natacha WEXELS-RISER